ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
ក្រុមប្រឹក្សាភិបាលមូលនិធិកាតព្វកិច្ច
សេវាសកលទូរគមនាគមន៍
លេខ៖ ០០៣/១៩ ក.ម.ក.ស.ទ.ស.ជ.ណ.

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបង់វិភាគចូលមូលនិធិកាតព្វកិច្ចសេវាសកលទូរគមនាគមន៍ (មូលនិធិ ក.ស.ទ.) និងមូលនិធិការកសាងសមត្ថភាពនិងការស្រាវជ្រាវនិងការអភិវឌ្ឍវិស័យទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (មូលនិធិ ស.អ.) ឆ្នាំ២០១៨

ក្រុមប្រឹក្សាភិបាលមូលនិធិកាតព្វកិច្ចសេវាសកលទូរគមនាគមន៍ (ក.ម.ក.ស.ទ.) និងក្រុមប្រឹក្សាមូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (ក្រុមប្រឹក្សា ស.អ.) សូមជម្រាបជូន អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី ជានាយកប្រតិបត្តិនៃប្រតិបត្តិករទូរគមនាគមន៍ ជ្រាបថា អនុលោមតាមសេចក្តីជូនដំណឹងលេខ០១៣/១៨ ក.ម.ក.ស.ទ. ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ និងសេចក្តីជូនដំណឹងលេខ០៣១/១៨ ក.ម.ស.អ. ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ ប្រតិបត្តិករទូរគមនាគមន៍ ត្រូវបង់វិភាគទានមកមូលនិធិកាតព្វកិច្ចសេវាកលទូរគមនាគមន៍ (មូលនិធិក.ស.ទ.) និងមូលនិធិនៃការកសាងសមត្ថភាព និងការស្រាវជ្រាវនិងការអភិវឌ្ឍលើវិស័យទូរគមនាគមន៍និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (មូលនិធិ ស.អ.) សម្រាប់ឆ្នាំ២០១៨ ជា ០៤ (បួន) ដំណាក់កាលដូចខាងក្រោម៖

-ដំណាក់កាលទី១៖ យ៉ាងយូរត្រឹមថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨
-ដំណាក់កាលទី២៖ យ៉ាងយូរត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៨
-ដំណាក់កាលទី៣៖ យ៉ាងយូរត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨
-ដំណាក់កាលទី៤៖ យ៉ាងយូរត្រឹមថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៩។

គិតត្រឹមថ្ងៃពេលនេះ ប្រតិបត្តិករទូរគមនាគមន៍ភាគច្រើនបានមកបំពេញកាតព្វកិច្ចបង់វិភាគទានចូលមូលនិធិ ក.ស.ទ. និងមូលនិធិ ស.អ. សម្រាប់ឆ្នាំ២០១៨ ដោយឡែកនៅមានប្រតិបត្តិករមួយចំនួនផ្សេងទៀតនៅពុំទាន់បានមកអនុវត្តកាតព្វកិច្ចបង់វិភាគទានចូលមូលនិធិទាំងពីររបស់ខ្លួន ស្របតាមការកំណត់ខាងលើឱ្យបានពេញលេញនៅឡើយទេ។

ហេតុដូចនេះ ក.ម.ក.ស.ទ. និងក្រុមប្រឹក្សាមូលនិធិ ស.អ. សូមធ្វើការរំលឹកដល់ **អ្នកឧកញ៉ា លោកឧកញ៉ា លោក លោកស្រី** ជានាយកប្រតិបត្តិនៃប្រតិបត្តិករទូរគមនាគមន៍ ត្រូវឆាប់រួសរាន់មកបំពេញកាតព្វកិច្ចបង់វិភាគទានចូលមូលនិធិទាំងពីរ (មូលនិធិ ក.ស.ទ. និងមូលនិធិ ស.អ.) សម្រាប់ឆ្នាំ២០១៨ យ៉ាងយូរត្រឹមថ្ងៃទី៣០ ខែមីនា ឆ្នាំ


អគារលេខ ១៣ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ. ទូរស័ព្ទ (៨៥៥) ២៣-៧២៤៨១០/៤២៦៥១០
ទូរសារ (៨៥៥) ២៣-៧២៤០៦៩

២០១៩ ស្របតាមសេចក្តីជូនដំណឹងខាងលើ។ ផុតរយៈពេលកំណត់នេះ ក.ម.ក.ស.ទ. និងក្រុមប្រឹក្សាមូលនិធិ ស.អ. នឹងចាត់វិធានការស្របតាមច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

ជាថ្មីម្តងទៀត ក.ម.ក.ស.ទ. និងក្រុមប្រឹក្សាមូលនិធិ ស.អ. សង្ឃឹមយ៉ាងមុតមាំថា ប្រតិបត្តិករទូរគមនាគមន៍ នឹងរួសរាន់មកបំពេញកាតព្វកិច្ចរបស់ខ្លួនតាមកាលបរិច្ឆេទកំណត់។៚

ថ្ងៃពុធ ៩កើត ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ២០១៩

**ជ.ក្រុមប្រឹក្សាមូលនិធិ ស.អ. និង ក.ម.ក.ស.ទ.**
**ប្រធាន**

ក្រាំ អ៊ិនទីត

**ចំលងជូន៖**
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ក្រសួងប្រៃណីយ៍និងទូរគមនាគមន៍
-អនុប្រធាននិងសមាជិករបស់ ក.ម.ក.ស.ទ. និងក្រុមប្រឹក្សាមូលនិធិ ស.អ.
- ប្រតិបត្តិករទូរគមនាគមន៍ទាំងអស់